# សុន្ទរកថា

## ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ក្នុងឱកាសអបអរសាទរ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៨

***នៅពហុកីឡាដ្ឋាន ជាតិអូឡាំពិក រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨***

- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ដែលមានវត្តមានទាំងអស់ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងការប្រើប្រាស់ និងការចរាចរគ្រឿងញៀនខុសច្បាប់ ថ្ងៃទី២៦ មិថុនា ឆ្នាំ២០០៨ ដែលរួមសហការរៀបចំដោយសាលាក្រុងភ្នំពេញ និងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិមួយចំនួនក្នុងពេលនេះ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមធ្វើការកោតសរសើរ និងវាយតំលៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរួមសហការរៀបចំអោយមានពិធីដ៏អធិកអធមនេះ ។ ជាមួយគ្នានេះ តាមរយៈ សុន្ទរកថាជាបន្តបន្ទាប់ទាំងរបស់តំណាងស្ថាប័នរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិសុទ្ធតែបានបង្ហាញពីជំហរ និងឆន្ទៈច្បាស់លាស់ក្នុងការចូលរួមចំណែកយ៉ាងសកម្មប្រយុទ្ធប្រឆាំងនឹងការផលិត ការចរាចរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ។ សកម្មភាពចូលរួមទាំងអស់នេះឆ្លុះ បញ្ចាំងអោយយើងឃើញថានេះជាការរួមសហការគ្នាជាធ្លុងមួយពីគ្រប់កំលាំងសរុបក្នុងសង្គមជាតិចូលរួមដោះស្រាយបញ្ហាគ្រឿងញៀន ។ ខ្ញុំក៏សូមយកឱកាសនេះថ្លែងនូវការកោតសរសើរដោយស្មោះស្ម័គ្រ និងអំណរគុណដ៏ជ្រាលជ្រៅចំពោះស្ថាប័នមានសត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

ពាក់ព័ន្ធនឹងអត្ថន័យ នៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿញៀនរបស់យើងក្នុងពេលនេះ គឺដោយហេតុថា និន្នាការ នៃការផលិត ការចរាចរជួញដូរ និងការប្រើបំពានគ្រឿងញៀននៅលើពិភពលោកកាន់តែមានការវិវត្តន៍ប្រែប្រួល និងបន្តបង្កនូវវិនាសកម្ម និងវិបត្តិជាច្រើន

ចំពោះសង្គមជាតិនោះ មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៨៧ បានកំណត់យកថ្ងៃទី២៦ មិថុនា ជារៀងរាល់ឆ្នាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងការប្រើបំពាននិងការចរាចរគ្រឿងញៀន ខុសច្បាប់ ដើម្បីរំលឹក និងផ្សព្វផ្សាយ ដល់មនុស្សជាតិទាំងអស់នៅលើពិភពលោកអោយបានយល់ដឹង ជ្រួតជ្រាបពីគ្រោះថ្នាក់ធ្ងន់ធ្ងរដែលបង្កឡើងដោយគ្រឿងញៀន និងផ្តល់នូវវិធីសាស្ត្រមួយចំនួន ដើម្បី ជួយអោយជីវិតយើង និងសង្គមយើងចៀសផុតពីការគំរាមកំហែងនៃគ្រឿងញៀន ។ ក្នុងន័យនេះ ការិយាល័យត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម អង្គការសហប្រជាជាតិតែងតែបានដាក់ចេញនូវ ពាក្យស្លោក និងប្រធានបទជាមគ្គុទេសក៍ ក្នុងកិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំឆ្នាំនីមួយៗ ជា រៀងរាល់ឆ្នាំដែលឆ្នាំនេះ ក៏ដូចជាឆ្នាំកន្លងទៅ គឺបានតម្រូវលើប្រធានបទដែលមានន័យថា " ***តើគ្រឿងញៀនត្រួតត្រាជីវិតអ្នកឬ ?*** " ជាមួយនេះ ការិយាល័យត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្ម អង្គការសហប្រជាជាតិ ក៏បានកំណត់យកនូវពាក្យ ស្លោកមួយផងដែរ គឺ " ***ជីវិតអ្នក–សហគមន៍ អ្នកគ្មានគ្រឿងញៀន*** " ។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ***

គ្រឿងញៀនជាបញ្ហាសកល ។ គ្រឿងញៀនបានជះឥទ្ធិពលអវិជ្ជមាន ដល់បណ្តាប្រទេស ទាំងអស់ក្នុងទ្រង់ទ្រាយ និងវិសាលភាពខុសៗគ្នា ទៅតាមតំបន់ និងតាមប្រទេសនីមួយៗ ។និន្នាការ នៃ ការប្រើបំពានគ្រឿងញៀននៅទូទាំងសកលលោក ជាពិសេសក្នុងចំណោមកុមារ និងយុវជនកំពុង មានការប្រែប្រួលក្នុងរយៈពេល ២0ឆ្នាំ ចុងក្រោយនេះ។

ដោយឡែកកម្ពុជាយើងក៏កំពុងតែជួបប្រទះនូវបញ្ហានេះដែរ ។ គ្រឿងញៀនដែលប្រើ ច្រើនជាងគេនៅកម្ពុជាគឺ មេតំហ្វេតាមីន រឺហៅម្យ៉ាងទៀតថាថ្នាំឆ្កួត (យ៉ាម៉ា/យ៉ាបា) ។ បញ្ហានេះ បានបង្កអោយមានបទឧក្រិដ្ឋ អំពើហឹង្សា ចោរកម្ម ព្រមទាំងការបាត់បង់នូវសណ្តាប់ធ្នាប់ សន្តិសុខ សង្គម ។ ជាមួយគ្នានេះ យើងក៏បានដឹងដែរថា បញ្ហាចាក់គ្រឿងញៀនតាមសរសៃកំពុងតែចាប់ផ្តើម មាននៅក្នុងចំណោមយុវជន ដែលបញ្ហានេះ មានឥទ្ធិពលយ៉ាងខ្លាំងក្នុងការចម្លងមេរោគអេដស៍/ ជម្ងឺអេដស៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការប្រើសុីរាំង–ម្ជុលរួមគ្នា ។ បទពិសោធន៍ នៅក្នុងប្រទេសជាច្រើនក្នុងតំបន់ និងក្នុងសកលលោកបានបញ្ជាក់ថា លទ្ធភាពនៃការឆ្លងមេរោគ អេដស៍ក្នុងចំណោមក្រុមចាក់គ្រឿងញៀននេះអាចមានរហូតដល់ ៥0% ឬលើសពីនេះ ក្នុងរយៈពេល តែមួយឆ្នាំប៉ុណ្ណោះ ។ កម្ពុជាត្រូវតែជៀសវាងអោយបានជាដាច់ខាតនូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនេះ ។ ដូច្នេះ ដើម្បីអោយយើងអាចចៀសផុតពីការត្រួតត្រា ញាំញីពីគ្រឿងញៀនបាន លុះត្រាធ្វើយ៉ាងណា អោយ " ***ជីវិតយើង–សហគមន៍យើង គ្មានគ្រឿងញៀន*** " ។

កន្លងមកនេះ ដើម្បីកសាងសហគមន៍គ្មានគ្រឿងញៀន រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវវិធានការជាច្រើនដូចជាការជំរុញអោយបង្កើតមជ្ឈមណ្ឌល ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅគ្រប់ខេត្ត–ក្រុង, ការបង្កើតគណៈកម្មការ

ត្រួតពិនិត្យគ្រឿងញៀននៅតាមគ្រប់សាលារៀន និងពិសេសនោះ គឺផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដែលមានគោលដៅចំបងគឺប្រែក្លាយសហគមន៍ ដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនអោយក្លាយទៅជាសហគមន៍ស្អាតស្អំ និងថែរក្សាសហគមន៍ស្អាតស្អំនោះមិនអោយមានការពាក់ព័ន្ធនឹងគ្រឿងញៀន ។ នេះគឺជាផ្នែកមួយនៃយន្តការរបស់យើងក្នុងការកសាង និងថែរក្សាសហគមន៍គ្មានគ្រឿងញៀន ។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ***

ទោះបីយ៉ាងណា យន្តការ និងផែនការខាងលើនេះនឹងពុំអាចទទួលបានជោគជ័យទេ ប្រសិនបើគ្មានការចូលរួមសហការពីកំលាំងសរុប ដែលចេញមកពីគ្រប់សមាសភាពសង្គមទេនោះ ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ធ្វើការណែនាំចំពោះស្ថាប័នមានសមត្ថកិច្ច និងកងកំលាំងទាំងអស់ដូចតទៅ :

***ចំពោះស្ថាប័នអនុវត្តន៍ច្បាប់ :***

- ត្រូវធ្វើការបង្ក្រាប និងផ្តន្ទាទោសអោយបានធ្ងន់ធ្ងរចំពោះ អ្នកផលិត ចរាចរ និងចែកចាយគ្រឿងញៀន ។
- ចូលរួមធ្វើការព្យាបាលអ្នកប្រើគ្រឿងញៀន ដោយចាត់ទុកពួកគេ មិនមែនជាឧក្រិដ្ឋជន។ ត្រូវជួយពួកគេ និងគ្រួសាររបស់គេអោយនៅឆ្ងាយពីគ្រឿងញៀន ដោយបញ្ជូនពួកគេទៅកាន់មជ្ឈមណ្ឌលព្យាបាល ឬ ទីវត្តអារាមដើម្បីជួយអប់រំតាមផ្លូវធម៌។
- ក្នុងនាមមន្ត្រីអនុវត្តច្បាប់ ត្រូវគោរពវិន័យ ក្រមសីលធម៌វិជ្ជាជីវៈ និងច្បាប់ មិនត្រូវពាក់ព័ន្ធនឹងបទល្មើសណាមួយឡើយ ហើយក៏មិនត្រូវអត់អោន យោគយល់ ចំពោះកងកំលាំងសមត្ថកិច្ចណាដែលឆ្លៀតប្រើប្រាស់តួនាទីរបស់ខ្លួនប្រព្រឹត្តបទល្មើស ឬធ្វើសកម្មភាពផ្ទុយនឹងវិជ្ជាជីវៈរបស់ខ្លួននោះទេ ជនប្រភេទនេះត្រូវអនុវត្តតាមវិធានការច្បាប់អោយបានធ្ងន់ធ្ងរបំផុត ។

***ចំពោះស្ថាប័នបំរើការងារសេវាសុខភាព :***

ខ្ញុំដឹងថា យើងធ្វើការងារបានល្អក្នុងការកាត់បន្ថយការឆ្លងរាលដាលមេរោគអេដស៍ក្នុងពេលកន្លងមកនៅក្នុងប្រទេសរបស់យើង ដែលនេះជាមោទនៈភាពរបស់ជាតិយើង ។ ឥឡូវ ខ្ញុំស្នើសុំអោយយកចិត្តទុកដាក់ចំពោះបញ្ហាគ្រឿងញៀនដោយធ្វើការសិក្សាពីមូលដ្ឋាន នៃការព្យាបាលអ្នកញៀននិងរោគសញ្ញាញៀនផ្សេងៗ ដោយចុះធ្វើការព្យាបាលនិងពិគ្រោះយោបល់នៅក្នុងសហគមន៍ផ្ទាល់ ។

***ចំពោះលោកគ្រូអ្នកគ្រូខ្ញុំស្នើថា :***

- សូមធ្វើការអប់រំ និងបណ្តុះបណ្តាលអោយសិស្សមានទំនុកចិត្តលើខ្លួនឯង ។ ផ្តល់នូវការអប់រំអោយសិស្សយល់ច្បាស់អំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននិងណែនាំពួកគេអោយចេះធ្វើការសំរេចចិត្តអោយបានត្រឹមត្រូវ ។
- ណែនាំ និងជួយអោយសិស្សមានក្រុមមិត្តអប់រំមិត្តក្នុងសាលា ដើម្បីអោយពួកគេអាចជួយ

គ្នាទៅវិញទៅមកក្នុងការប្រឆាំងនឹងការប្រើបំពានគ្រឿងញៀន ។

***ចំពោះឪពុកម្តាយ និងក្រុមគ្រួសារខ្ញុំស្នើថា :***

យើងមិនត្រូវភ្លេចគិតពីកូនចៅរបស់យើងទេ ទោះបីយើងមមាញឹកខ្លាំងក្នុងការប្រកបរបរផ្គត់ផ្គង់គ្រួសារក៏ដោយ ព្រោះពួកគេជាទ្រព្យដ៏មានតម្លៃបំផុតរបស់យើងនៅក្នុងលោកនេះ ។ ត្រូវផ្តល់នូវសេចក្តីស្រលាញ់ដែលមានព្រំដែនដល់ពួកគេ ។ សូមអប់រំកូនចៅរបស់យើងអោយបដិសេធន៍ការប្រើគ្រឿងញៀន ត្រូវអប់រំកូនចៅយើងអោយយល់ពីតំលៃរបស់មនុស្ស និងជិនាញជីវិតរបស់ខ្លួន និងត្រូវផ្តល់នូវក្តីស្រលាញ់ និងការថៃទាំដើម្បីអោយកូនចៅយើងអភិវឌ្ឍន៍ខ្លួនទៅជាពលរដ្ឋល្អប្រកបដោយសុខភាពមាំមួន ។

***ចំពោះក្មួយៗសិស្សានុសិស្ស :***

អ៊ំ ពូ ដឹងថា ក្មួយៗ កំពុងរស់នៅក្នុងពិភពលោកដ៏ទំនើបមួយ ។ ស្ថិតក្នុងយុគសម័យទំនើបនេះ ក្មួយៗត្រូវចេះទាញយកផលប្រយោជន៍ពីការរីកចំរើនបច្ចេកវិទ្យាមកបង្កើនសមត្ថភាពផ្ទាល់ខ្លួន ដើម្បីប្រែក្លាយខ្លួនអោយទៅជាពលរដ្ឋល្អប្រកបដោយថាមពល និងបញ្ញាញាណ ជាធនធានដ៏មានសក្តានុពលសំរាប់គ្រួសារ និងសង្គមជាតិ ។ ជាចុងបញ្ចប់ អ៊ំ ពូ សូមផ្តាំថា ***បើស្រលាញ់ខ្លួន ស្រលាញ់ឪពុកម្តាយ ត្រូវចៀសអោយឆ្ងាយពីគ្រឿងញៀន ត្រូវមានការទទួលខុសត្រូវចំពោះ ខ្លួនឯង ចំពោះមិត្តភក្តិ និងត្រូវចេះណែនាំគ្នាទៅវិញទៅមកអំពីគ្រោះថ្នាក់នៃការប្រើគ្រឿងញៀន ។***

តាមរយៈការណែនាំ និងសំណូមពរនេះ ខ្ញុំសង្ឃឹមថា យើងនឹងអាចចូលរួម កសាងជីវិត និងសហគមន៍ របស់យើងគ្មានគ្រឿងញៀនគ្រប់ៗគ្នាជាក់ជាមិនខាន ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ អស់លោកលោកស្រី កងកំលាំងប្រដាប់អាវុធ បងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ និងក្មួយៗយុវជនសិស្សានុសិស្សទាំងអស់ជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរគុណ !***